គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP
IDA - KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - PDP- PJJ - VIGILANCE
#9, St.330, Boeng Keng Kong III, Chamcar Morn, P.P Tel/Fax: (023) 218 759, Tel: 30 14 15, E-mail: chrac@forum.org.kh, chracsecretariat@yahoo.com

# សេចក្តីថ្លែងការណ៍

## ការព្រួយបារម្ភជុំវិញការបណ្តេញប្រជាពលរដ្ឋ ២១៤ គ្រួសារចេញពីភូមិអូរបាត់មាន់ សង្កាត់កូនគ្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលរួមមានអង្គការ-សមាគមមិនមែនរដ្ឋាភិបាល ចំនួន ២១ ជាសមាជិក សូមសំដែងនូវការមិនពេញចិត្តចំពោះទង្វើរបស់អាជ្ញាធរខេត្តឧត្តរមានជ័យ ដែលបានបណ្តេញប្រជាពលរដ្ឋដោយបង្ខំនៅក្នុងសង្កាត់កូនគ្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ ហើយបានចាប់ឃុំខ្លួនតំណាងប្រជា ពលរដ្ឋ ចំនួន ៣ នាក់ និង មានការវាយដំឱ្យរងរបួស ចំនួន ២ នាក់ ចំណែកឯប្រជាពលរដ្ឋមួយចំនួនផ្សេងទៀត កំពុងរត់គេចខ្លួន នៅក្នុងព្រៃ ដោយសារមានការភ័យខ្លាចពីការចាប់ខ្លួន។

កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ អាជ្ញាធរចំរុះខេត្តឧត្តរមានជ័យ ប្រដាប់ដោយអាវុធវែង-ខ្លី ដោយមានការចូលរួមពីមន្ត្រីតុលាការខេត្តសៀមរាបផង បានចុះទៅកំទេច និង ដុតបំផ្លាញផ្ទះសំបែងរបស់ប្រជាពលរដ្ឋ ចំនួន ២១៤ គ្រួសារ ដើម្បីយកដីប្រគល់ទៅឱ្យក្រុមហ៊ុនអង្គរស៊ូហ្គ័រ (Angkor Sugar) ដែលក្រុមហ៊ុននេះបានទទួលដីសម្បទានសេដ្ឋកិច្ចពីរាជរដ្ឋាភិបាល ទំហំ ១0000 ហិចតា ដើម្បីអភិវឌ្ឍន៍ដាំដំណាំអំពៅ នៅលើដីដែលប្រជាពលរដ្ឋកំពុងរស់នៅ និងអាស្រ័យផលដំណាំដែលប្រជាពលរដ្ឋបានដាំដុះជាច្រើនឆ្នាំមកហើយ។ នៅក្នុងព្រឹត្តការណ៍នៃការបណ្តេញចេញនោះ អាជ្ញាធរបានរារាំងដល់ក្រុមសិទ្ធិមនុស្សមិនត្រូវបានគេអនុញ្ញាតឱ្យចូលទៅឃ្លាំមើលការបណ្តេញនេះឡើយ។ ប្រជាពលរដ្ឋដែលត្រូវបានបណ្តេញចេញទាំងនោះបានទៅស្នាក់នៅបណ្តោះអាសន្ននៅក្នុងទីវត្តអារាមមួយ ឈ្មោះថា វត្តគោកភ្លុក ដែលស្ថិតនៅក្រៅវង្វង់ដីសម្បទាន ហើយកាលពីម្សិលមិញនេះ ពួកគាត់ទទួលរងនូវការបណ្តេញចេញម្តងទៀតពីវត្តគោកភ្លុកទៅកាន់កន្លែងមួយផ្សេងទៀត ហើយបច្ចុប្បន្នប្រជាពលរដ្ឋទាំងនោះកំពុងរងនូវការលំបាកវេទនា ដោយខ្វះទឹក ខ្វះអាហារ ទីជំរក និង ថ្នាំសង្កូវផ្សេងៗ ចំណែកប្រជាពលរដ្ឋមួយចំនួនទៀតបានធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ ដើម្បីសុំកិច្ចអន្តរាគមន៍ពីស្ថាប័នមានសមត្ថកិច្ចផ្សេងៗ។

យោងតាមពត៌មានដែលគណៈកម្មាធិការប្រព្រឹត្តិកម្មទទួលបានថា អាជ្ញាធរបាន និង កំពុងគំរាមកំហែងប្រជាពលរដ្ឋដែលកំពុងស្នាក់នៅទីវត្តអារ៉ាមនោះឱ្យយល់ព្រមផ្តិតមេដៃទទួលយកដីតាមគោលនយោបាយរបស់អាជ្ញាធរខេត្ត ដែលមានទំហំដីលំនៅដ្ឋានទំហំ ៣0 x ៥0ម៉ែត្រ និង ដីស្រែទំហំ ១ ហិចតា ក្នុង ១ គ្រួសារ។ មានតែប្រជាពលរដ្ឋ ចំនួន ៣៩ គ្រួសារប៉ុណ្ណោះដែលត្រូវបានទទួលគោលនយោបាយនេះ ចំណែកប្រជាពលរដ្ឋផ្សេងទៀតមិនត្រូវបានពិចារណាឡើយ។ ដោយឡែកប្រជាពលរដ្ឋបានទាមទារ ឱ្យមានការដោះស្រាយនូវដីស្រែទំហំ ៥ ហិចតា ក្នុងមួយគ្រួសារ និង ចំនួន ២១៤ គ្រួសារ ព្រមទាំងសងនូវទ្រព្យសម្បត្តិដែលបាន រងការខូចខាត និង សត្វចិញ្ចឹមផ្សេងៗរបស់ពួកគាត់ផងដែរ។

គណៈកម្មាធិការប្រព្រឹត្តិកម្មយល់ឃើញថា ការបណ្តេញចេញដោយបង្ខំ និង ការដុតបំផ្លាញផ្ទះសំបែងរបស់ប្រជាពលរដ្ឋការគំរាមកំហែងផ្សេងៗ គឺជាការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ជាពិសេសសិទ្ធិមានលំនៅដ្ឋានសមរម្យ។

គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមសំណូមពរដល់រាជរដ្ឋាភិបាល អាជ្ញាធរខេត្ត និង អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ មេត្តាជួយធ្វើអន្តរាគមន៍ ឱ្យបញ្ឈប់ជាបន្ទាន់នូវការតាមចាប់ខ្លួន និង ការគំរាមកំហែងលើប្រជាពលរដ្ឋ ព្រមទាំងដោះលែងតំណាងប្រជាពលរដ្ឋដែលបានចាប់ខ្លួនឱ្យមានសេរីភាពឡើងវិញ។ គណៈកម្មាធិការប្រព្រឹត្តិកម្មសូមសំណូមពរផងដែរឱ្យមានការដោះស្រាយដីធ្លីជូនប្រជាពលរដ្ឋរងគ្រោះក្រីក្រទាំងនោះឱ្យបានឆាប់រហ័ស និង យុត្តិធម៌ ដែលអាចទទួលយកបានតាមអនុក្រិត្យដែលបានចែង ព្រោះរាជរដ្ឋាភិបាលមានដីរាប់ម៉ឺនហិចតាដើម្បីផ្តល់សម្បទានសេដ្ឋកិច្ចឱ្យទៅក្រុមហ៊ុនឯកជន ដូច្នេះការផ្តល់ដីសម្បទានសង្គមកិច្ចឱ្យបានគ្រប់គ្រាន់ជូនប្រជាពលរដ្ឋក្រីក្រដើម្បីបង្កបង្កើនផលចិញ្ចឹមជីវិតនោះ គណៈកម្មាធិការប្រព្រឹត្តិកម្មសង្ឃឹមយ៉ាងមុតមាំថា អាជ្ញាធរខេត្តនឹងធ្វើការពិចារណាដោះស្រាយជូនពួកគាត់ ប្រកបដោយសុភ័ក្រវិនិច្ឆ័យ។

ភ្នំពេញ, ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៩

☏ ***សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង:***

| | | |
|---|---|---|
| -លោក **ហង្ស ឆាយា** | ប្រធាន សំរបសំរួលគណៈកម្មាធិការប្រព្រឹត្តិកម្ម CHRAC | |
| | និង នាយកប្រតិបត្តិ KID | ទូរស័ព្ទលេខ: ០១២ ៨៦៥ ៩១០ |
| -លោក **ធន សារាយ** | ប្រធាន សមាគមអាដហុក ADHOC | ទូរស័ព្ទលេខ: ០១៦ ៨៨០ ៥០៩ |
| -លោក **សុក សំអឿន** | នាយកប្រតិបត្តិ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា CDP | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| -លោកស្រី **សយ សារាវឌ្ឍនី** | នាយិកាប្រតិបត្តិ អង្គការកម្ពុជា ដើម្បីជួយស្ត្រីមានវិប្បត្តិ CWCC | ទូរស័ព្ទលេខ: ០៩២ ៩៩៣ ៣៥៨ |